# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

មជ្ឈមណ្ឌលភ្នំពេញ, អាគារ  (A) , វិថី

សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន

ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៩៣

**លេខ និងឈ្មោះសំណុំរឿង : ៦៤/០៥ - ជាន វៃ ស៊្វីស**

**កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី ៣០  ខែ វិច្ឆិកា ឆ្នាំ ២០០៥**

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១-  ភាគីនិយោជក**

ឈ្មោះ :   ក្រុមហ៊ុន ជាន វៃ ស៊្វីស

អាសយដ្ឋាន : ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១១ ៩៧៦ ៣៦៦   ០១២ ១៩៥៧ ៩៣១   ០២៣ ៨០២ ១១៨

ទូរសារ : ០២៣ ៨០២ ១១៦ ។

**តំណាងភាគីនិយោជក :**

១-លោក ខា កុកឃាង     រដ្ឋបាលក្រុមហ៊ុន

២-កញ្ញា គុំ វណ្ណារី     គណនេយ្យក្រុមហ៊ុន

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : សហព័ន្ធសហជីពខ្មែរ និង សហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វៃ

អាសយដ្ឋាន : អគារលេខ ៩ ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០២៣ ៨៨៣ ១៥៣   ០១២ ៦៥៨ ១២៩   ០១២ ៧១១ ៤៨៥

ទូរសារ : ០២៣ ៨៨៣ ១៥៣ ។

**តំណាងកម្មករនិយោជិត :**

| | |
|---|---|
| ១- លោក ម៉ុម ធន | មន្ត្រីដោះស្រាយវិវាទនៃសហព័ន្ធសហជីពខ្មែរ |
| ២- លោក មាស ភក្តី | មន្ត្រីដោះស្រាយវិវាទនៃសហព័ន្ធសហជីពខ្មែរ |
| ៣- លោក ប៉ែន សុភា | មន្ត្រីដោះស្រាយវិវាទនៃសហព័ន្ធសហជីពខ្មែរ |
| ៤- លោក យ៉ិក ម៉ៅ | ប្រធានសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វៃ |
| ៥- លោក រិន វណ្ណា | អនុប្រធានសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វៃ |
| ៦- លោក តេន រាម | លេខាធិការសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វៃ |
| ៧- លោក នួន សារ៉ាន់ | លេខាធិការរងសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វៃ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

យោងតាមកំណត់ហេតុក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ចំណុចបញ្ហាមិនសះជាខាងក្រោម ជាការទាមទាររបស់ភាគីកម្មករនិយោជិតនៃសំណុំរឿងវិវាទៈ

១- ភាគីកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតចំនួន ០៤នាក់ ដែលមានឈ្មោះ លោក រិន វណ្ណា លោក តេន រាម លោក នួន សារ៉ាន់ និងលោក យ៉ិក ម៉ៅ ឱ្យចូលធ្វើការវិញ ដោយលើកហេតុផលថា ការបញ្ឈប់នេះគ្មានមូលហេតុសមស្រប ។ ដោយឡែកភាគីក្រុមហ៊ុនបានអះអាងថា ក្រុមហ៊ុនមិនអាចទទួលយកកម្មករទាំង៤នាក់ខាងលើចូលធ្វើការវិញឡើយ ដោយលើកហេតុផលថា កម្មករទាំង៤នាក់នេះ បានអុកឡុកក្រុមហ៊ុន និងមិនស្តាប់បង្គាប់តាមការណែនាំរបស់ក្រុមហ៊ុន ទន្ទឹមនឹងនេះ ក្រុមហ៊ុនផ្តល់ជូនតែប្រាក់ឈ្នួលខែចុងក្រោយ និងប្រាក់ជួសការឈប់សំរាកប្រចាំឆ្នាំប៉ុណ្ណោះ ។

២- ភាគីកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុនសង់បង្គន់បន្ថែមសំរាប់បុរស និងស្ត្រី ឱ្យសមស្របតាមប្រកាសលេខ ០៥២ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំបង្គន់អនាម័យតាមចំនួនសមាមាត្រដូចមានចែងក្នុងប្រកាសនោះ ។

៣- ភាគីកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុនដាក់កន្លែងចតកង់ម៉ូតូនៅក្បែរប៉ុស្តិ៍យាម ជៀសវាងការដឹកម៉ូតូ ដើរឆ្ងាយហួសហេតុពេក ធ្វើឱ្យខាតពេលវេលាកម្មករ ។

៤- ភាគីកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុននៅពេលបញ្ឈប់កម្មករនិយោជិតណាម្នាក់ ត្រូវមានកំហុសគ្រប់គ្រាន់សមហេតុផលតាមផ្លូវច្បាប់ ។

៥- ភាគីកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុនសហការល្អជាមួយសហជីពមូលដ្ឋាន ( សហព័ន្ធសហជីពខ្មែរ) ដើម្បីនាំមកនូវស្ថេរភាពល្អ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាម ជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ ( អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៥២៨ ក.ក.ប.វ/វ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ:** -ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ ( វេលាម៉ោង ១៤:០០ ដល់ម៉ោង ១៧:៣០ នាទី)
-ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ( វេលាម៉ោង ៨:០០ ដល់ម៉ោង ១២:០០ នាទី) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ សហព័ន្ធសហជីពខ្មែរ បានធ្វើពាក្យបណ្តឹងទៅនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលចំណុចវិវាទមានចំនួន០៦ចំណុច ។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ មន្ត្រីនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះដល់ក្រុមហ៊ុន ជាន វៃ ដើម្បីធ្វើការផ្សះផ្សាវិវាទការងាររួម ហើយលទ្ធផលនៃការផ្សះផ្សាទទួលបានការសះជា ចំនួន០២ចំណុច នៅសល់០៤ចំណុច បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីដោះស្រាយបន្តតាមច្បាប់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីវិវាទទាំងពីរឱ្យចូលរួមសវនាការជាបន្តបន្ទាប់ គឺនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោង ១៤:០០ រសៀល និងនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៥ វេលាម៉ោង ៨:០០ព្រឹក នៅលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដំណើរការអាជ្ញាកណ្តាលដោះស្រាយវិវាទដែលមិនទាន់សះជានេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានលើកទឹកចិត្តដល់ភាគីទាំងពីរឱ្យបន្តការចរចានៅក្នុងសវនាការ រហូតទទួលបានការសះជាចំនួន ០៤ចំណុច នៅសល់០១ចំណុច គឺការបញ្ឈប់ថ្នាក់ដឹកនាំសហជីពចំនួន០៤នាក់ ដែលភាគីទាំងពីរនៅតែមិនអាចយោគយល់គ្នា និងមិនអាចទទួលបានលទ្ធផលសះជានឹងគ្នាទេ ។

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន ។

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចុះបញ្ជិកាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០០

២- លិខិតចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥ របស់ក្រុមហ៊ុន ជាន វ៉ៃ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើសុំជូនដំណឹងពីការបញ្ឈប់ការងារកម្មករចំនួន០៤នាក់

៣- អនុស្សារណ: និងលក្ខន្តិក: ក្រុមហ៊ុន ជាន វ៉ៃ

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥

៥- របាយការណ៍របស់ប្រធានសន្តិសុខក្រុមហ៊ុន ស្តីពីសកម្មភាពរបស់កម្មករទាំងបួនរូប ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥

៦- របាយការណ៍របស់ប្រធានសន្តិសុខក្រុមហ៊ុន ស្តីពីសកម្មភាពរបស់លោក នួន សារ៉ាន់ ចុះថ្ងៃទី២៨ និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥

៧- របាយការណ៍របស់លោក តាំង សៀងយ៉ុង ជាអ្នកបកប្រែ ស្តីពីលោក តេន រាម និងលោក រិន វណ្ណា ដែលបានពង្រាយសំបកសណ្តែកដីនៅកន្លែងធ្វើកានៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥

៨- ប្រវត្តិរូបសង្ខេបរបស់លោក រិន វណ្ណា និងអត្តសញ្ញាណប័ណ្ណលេខ ០១០៤៧៤៧២៩

៩- ប្រវត្តិរូបសង្ខេបរបស់លោក តេន រាម និងអត្តសញ្ញាណប័ណ្ណលេខ ០៦០៤៥០២៤៨

១០- ប្រវត្តិរូបសង្ខេបរបស់លោក នួន សារ៉ាន់ និងប័ណ្ណបោះឆ្នោតលេខ ៩៥៣២៥៦៥

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត

១- បង្កាន់ដៃទទួលសំណុំរឿង ស្តីពីការសុំចុះបញ្ជិកាសហជីពខ្មែរនៅក្រុមហ៊ុន ជាន វ៉ៃ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់នាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ:

២- លិខិតលេខ ១០២/០៥ សសខ ស្តីពីការជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វ៉ៃ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៥ របស់សហព័ន្ធសហជីពខ្មែរ

៣- ពាក្យបណ្តឹងរបស់លោក នួន សារ៉ាន់ ស្តីពីការប្តឹងក្រុមហ៊ុន ជាន វ៉ៃ រើសអើងមិនឱ្យថែមម៉ោង ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៥

៤- ពាក្យបណ្តឹងរបស់លោក យ៉ិក ម៉ៅ ស្តីពីការប្តឹងក្រុមហ៊ុន ជាន វ៉ៃ សង់បង្គន់តិច ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៥

៥- ពាក្យបណ្តឹងរបស់លោក រិន វណ្ណា ស្តីពីការប្តឹងក្រុមហ៊ុន ជាន វ៉ៃ ដែលបានផ្លាស់ប្តូរការងារទៅក្រុមផ្សេង រួចប្តូរមកក្រុមវិញ និងមិនឱ្យធ្វើការថែមម៉ោង ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៥

៦- កំណត់ហេតុស្តីពីការបង្កើតសហជីពខ្មែរនៃក្រុមហ៊ុន ជាន វ៉ៃ (កំណត់ហេតុគ្មានហត្ថលេខាអ្នកធ្វើ)

៧- ពាក្យសុំចុះបញ្ជិកាសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វ៉ៃ (គ្មានហត្ថលេខាអ្នកធ្វើពាក្យសុំ)

៨- បញ្ជីរាយនាមថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំក្រុមហ៊ុន ជាន វ៉ៃ (គ្មានហត្ថលេខាអ្នកធ្វើ) ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- លិខិតស្នើសុំឱ្យដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជាន វ៉ៃ លេខ ១៧៦៦ ក.ក.ប.វ របស់ឯកឧត្តម **ញ៉ែប ប៊ុនជិន** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥

២- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជាន វ៉ៃ លេខ៩២៨ ក.ក.ប.វ/អក/វក របស់លោក **កុយ ទេពដារ៉ាវុធ** ប្រធាននាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥

៣- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ៣៣៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ ៣៣៨ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ៣៤៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៥

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ៣៤៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៥

**អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

នៅក្នុងក្រុមហ៊ុន ជាន វៃ ស៊្វែស ខូអិលធីឌី មានកម្មករនិយោជិតសរុប ១.២១៥ នាក់ ។ កម្មករទាំងបួននាក់ ដែលត្រូវបណ្តេញចេញមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ពីព្រោះអតីតភាពការងាររបស់គេម្នាក់ៗមានរយៈពេលលើស ២ ឆ្នាំ និងមិនធ្វើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរទេ ។

ភាគីកម្មករអះអាងថា ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៥ វេលាម៉ោង ៩ ទៅម៉ោង ១០ ព្រឹក នៅសហព័ន្ធសហជីពខ្មែរ មានរៀបចំបង្កើតសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ និងបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពដែលមានសមាជិកស្ថាបនិកចំនួនជាងដប់នាក់ជាកម្មករកម្មការិនីក្នុងក្រុមហ៊ុន ជាន វៃ ចូលរួម។ លទ្ធផលនៃការបោះឆ្នោតគឺ លោក យ៉ិក ម៉ៅ ត្រូវជាប់ជាប្រធាន លោក រិន វណ្ណា ត្រូវជាប់ជាអនុប្រធាន លោក តេន រាម ត្រូវជាប់ជាលេខាធិការ និងលោក នួន សារ៉ាន់ ត្រូវជាប់ជាលេខាធិការរង ហើយបានយកលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំរោងចក្រ ដែលបានជាប់ឆ្នោតទៅជូននាយកក្រុមហ៊ុន ជាន វៃ តាមរយៈលិខិតជូនដំណឹងលេខ ១០២/០៥ សសខ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៥ ថា ការបោះឆ្នោតនោះប្រព្រឹត្តទៅនៅម៉ោង ៨ យប់ ។ ឯភាគីនិយោជកបានអះអាងថា ក្រុមហ៊ុនមិនដែលបានទទួលលិខិតនេះទេ ។

ប៉ុន្តែតាមការពិនិត្យលើសំណុំរឿង និងតាមការសាកសួរនាពេលសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា ការអះអាងរបស់ភាគីកម្មករដែលថា បានបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពកាលពីថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៥ នោះ ក្រុមប្រឹក្សាអជ្ញាកណ្តាលមិនអាចជឿបានទេ ពីព្រោះរាល់ឯកសារដែលមានក្នុងសំណុំរឿង ដូចជា ពាក្យបណ្តឹងរបស់សហព័ន្ធសហជីពខ្មែរ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៥ កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ និងរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទមិនសះជាចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៥ របស់នាយកដ្ឋានវិវាទការងារ ភាគីសហព័ន្ធសហជីពខ្មែរក៏ដូចជាកម្មករទាំងបួនរូបបានចុះតួនាទីអ្នកទាំងបួនរូបជាកម្មករ ដោយមិនបានតាំងខ្លួនជាថ្នាក់ដឹកនាំសហជីពឡើយ។ ម្យ៉ាងទៀតនៅក្នុងសវនាការភាគីកម្មករអះអាងថា ការបោះឆ្នោតនេះគឺធ្វើឡើងនៅពេលព្រឹក ហើយនៅក្នុងកំណត់ហេតុបោះឆ្នោតថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៥ បានសរសេរថា ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំសហជីពធ្វើឡើងនៅពេលព្រឹកដែរ ។ ប៉ុន្តែតាមរយៈលិខិតជូនដំណឹងដែលសហព័ន្ធសហជីពខ្មែរដាក់ចូលសំណុំរឿងកត់ត្រាថា ការបោះឆ្នោតធ្វើឡើងនៅម៉ោង ៨ ល្ងាច ទៅវិញ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនទទួលស្គាល់លើអង្គហេតុថា ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៥ មានការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ ឡើយ ។ មិនតែប៉ុណ្ណោះ ដោយការ

បោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ មិនមានភាពច្បាស់លាស់ និងដោយសារភាគីកម្មករមិនបានបង្ហាញភស្តុតាងបញ្ជាក់ថា ភាគីនិយោជកបានទទួលលិខិតជូនដំណឹងអំពីថ្នាក់ដឹកនាំសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលស្គាល់ថា ក្រុមហ៊ុនពិតជាមិនបានទទួលលិខិតជូនដំណឹងនេះមែន ។

នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលសំណុំរឿងសុំចុះបញ្ជិកាសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ ហើយរហូតមកដល់ពេលនេះ ក្រសួងការងារពុំទាន់បានចេញវិញ្ញាបនប័ត្រទទួលស្គាល់សហជីពនៅឡើយ ។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥ ភាគីនិយោជក បានបញ្ឈប់កម្មករចំនួន ៤ នាក់ ឈ្មោះ យ៉ិក ម៉ៅ ឈ្មោះ រិន វណ្ណា ឈ្មោះ តេន រាម និងឈ្មោះ នួន សារ៉ាន់ និងបានជូនដំណឹងអំពីការបញ្ឈប់នេះ ទៅនាយកដ្ឋានវិវាទការងារ ដោយផ្អែកលើកំហុស ៣ យ៉ាងគឺ (១)-ជិះម៉ូតូចូលក្នុងក្រុមហ៊ុន (២)-ហូបសណ្តែកដីនៅក្នុងកន្លែងធ្វើការ (៣)-ក្នុងម៉ោងធ្វើការសម្ងំក្នុងបន្ទប់ទឹក ។ ភាគីនិយោជកទទួលស្គាល់ថា ការបញ្ឈប់កម្មករទាំងបួននាក់នេះ គឺមិនបានអនុវត្តតាមបទបញ្ជាផ្ទៃក្នុងទេ ហើយក៏មិនបានធ្វើពាក្យសុំបញ្ឈប់ទៅអធិការការងារដែរ ពីព្រោះក្រុមហ៊ុនមិនបានទទួលការជូនដំណឹងអំពីថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ តាមច្បាប់ឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ក្នុងចំណោមថ្នាក់ដឹកនាំសហជីពទាំងបួននាក់នេះ មាន៣នាក់គឺ លោក តេន រាម លោក រិន វណ្ណា និងលោក នួន សារ៉ាន់ មានអាយុក្រោម ២៥ ឆ្នាំ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករទាំងបួននាក់នេះ គឺធ្វើឡើងមុនពេលដាក់ពាក្យសុំចុះបញ្ជិកានៅនាយកដ្ឋានវិវាទការងារ ។

នាពេលសវនាការ ភាគីនិយោជកឆ្លើយថា (១)-ចំពោះឈ្មោះ តេន រាម មានកំហុសជិះម៉ូតូក្នុងបរិវេណរោងចក្រ ហូបសណ្តែកដីនៅកន្លែងធ្វើការ និងសម្ងំនៅក្នុងបន្ទប់ទឹក ។ ឯ តេន រាម បានបដិសេធថា មិនបានហូបសណ្តែកដីនៅកន្លែងធ្វើការទេ ហើយបានទទួលស្គាល់ថា បានជិះម៉ូតូក្នុងបរិវេណរោងចក្រតែមួយដង និងបានជជែកគ្នានៅក្នុងបន្ទប់ទឹកប្រហែល២០នាទីមែន ។ (២)-ចំពោះឈ្មោះ នួន សារ៉ាន់ មានកំហុស ជិះម៉ូតូក្នុងបរិវេណរោងចក្រ និងសម្ងំក្នុងបន្ទប់ទឹក ។ នួន សារ៉ាន់ ទទួលស្គាល់ថា បានជជែកគ្នានៅក្នុងបន្ទប់ទឹកប្រហែល ២០ នាទី និងបានជិះម៉ូតូក្នុងបរិវេណរោងចក្រមែន តែមានកម្មករនិយោជិតជាច្រើនជិះម៉ូតូក្នុងបរិវេណរោងចក្រដូចគ្នា តែនិយោជកចាប់កំហុសតែពួកខ្លួនប៉ុណ្ណោះ ដោយសារពួកខ្លួនហ៊ានទាមទារតវ៉ាជាមួយនិយោជក ហើយពីមុនអ្នកដែលចូលសហជីពតែងតែត្រូវគេដេញចោល ។ (៣)-ចំពោះឈ្មោះ រិន វណ្ណា មានកំហុស ជិះម៉ូតូក្នុងបរិវេណរោងចក្រ ហូបសណ្តែកដីនៅកន្លែងធ្វើការ និងសម្ងំនៅក្នុងបន្ទប់ទឹក ។ ឯ រិន វណ្ណា បានបដិសេធថា មិនបានហូបសណ្តែកដីនៅកន្លែងធ្វើការ ហើយបានទទួលស្គាល់ថា បានជិះម៉ូតូក្នុងបរិវេណរោងចក្រ និងបានជជែកគ្នានៅក្នុង

បន្ទប់ទឹកប្រហែល ២០ នាទី មែន ។ (៤)-ចំពោះឈ្មោះ យ៉ិក ម៉ៅ មានកំហុសសម្ងំក្នុងបន្ទប់ទឹក ហើយជាមេក្លោងគេ ។ តែ យ៉ិក ម៉ៅ បានបដិសេធថា ខ្លួនមិនមែនជាមេក្លោងទេ ហើយបានទៅបន្ទប់ទឹក ដោយចៃដន្យបានជួបជាមួយអ្នកទាំងបីខាងលើបានតែបន្តិច បន្ទាប់មក ឈ្មោះ ខា កុកឃាង ជាប្រធានរដ្ឋបាល ក៏បានទៅដល់ហើយថតរូបពួកខ្លួនតែម្តង។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលស្គាល់ថា ពិតជាមានការជិះម៉ូតូចូលក្នុងបរិវេណរោងចក្រ និងមានការសម្ងំក្នុងបន្ទប់ទឹកមែន ។ ប៉ុន្តែ មិនទទួលស្គាល់លើអង្គហេតុដែលនិយោជកចោទប្រកាន់ថា អ្នកទាំងបីហូបសណ្តែកដីនៅកន្លែងធ្វើការទេ ពីព្រោះ (១)-សំបកសណ្តែកដីដែលនិយោជកថតមក គឺមិនមែននៅកន្លែងអ្នកទាំងបីធ្វើការទេ និង (២)-ពុំមានសាក្សីណា បានឃើញអ្នកទាំងបីនោះហូបសណ្តែកដីដែរ នេះគ្រាន់តែជាការសន្និដ្ឋាន របស់ភាគីនិយោជកតែប៉ុណ្ណោះ ។

## ហេតុផលនៃសេចក្តីសំរេច

នៅក្នុងចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវពិចារណាថា តើថ្នាក់ដឹកនាំសហជីពដែលត្រូវបញ្ឈប់ទាំងបួននាក់នេះ គួរទទួលបានការការពារតាមច្បាប់ដែរឬទេ? តើការបណ្តេញចេញកម្មករទាំងបួននាក់នេះត្រឹមត្រូវតាមច្បាប់ដែរឬទេ ?

*១-តើថ្នាក់ដឹកនាំសហជីពដែលត្រូវបញ្ឈប់ទាំងបួននាក់នេះ គួរទទួលបានការការពារតាមច្បាប់ដែរឬទេ?*

ប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ប្រការ ៣ កថាខ័ណ្ឌទី ៣ ចែងថា *" កម្មករនិយោជិតទាំងអស់ ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះ មានរយៈពេល ៤៥ ថ្ងៃមុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនោះ មិនត្រូវបានជាប់ឆ្នោត ..........."* ។ ប្រការ ៤ កថាខ័ណ្ឌទី ១ និង២ ចែងថា *"ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជិកាសហជីព កម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬ កម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា ត្រូវបានការការពារ ដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។ ការការពារនេះ មានរយៈពេលរហូតដល់ ៣០ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះបញ្ជិកាសហជីព ។*

*ផុតរយៈពេលកំណត់ក្នុងកថាខ័ណ្ឌខាងលើ ការការពារនេះត្រូវបានផ្តល់ឱ្យអ្នកដឹកនាំសហជីព ០៣ នាក់ក្នុងល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ ។ ចំពោះសហជីពដែលមានសមាជិក*

*លើសពី ២០០ នាក់ ការការពារនេះ ត្រូវផ្តល់ឱ្យសមាជិកសហជីពម្នាក់សំរាប់ភាគបន្ថែមនីមួយៗ ដែលមានសមាជិកសហជីព ១០០ នាក់ ................"* ។

**ផ្អែកតាមខ្លឹមសារនៃប្រកាសខាងលើឃើញថា ការការពារមានបីសណ្ឋានគឺៈ**

**ក-ការការពារចំពោះបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពៈ**

រាល់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ត្រូវទទួលបានការការពារ ៤៥ ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់៤៥ថ្ងៃក្រោយការបោះឆ្នោត (ប្រសិនបើបេក្ខជននោះមិនជាប់ឆ្នោត) ដូចជាប្រតិភូបុគ្គលិកដែរ ដូចជាការការពារទៅនឹងការបញ្ឈប់ការងារ ឬការផ្លាស់ប្តូរការងារជាដើម ។

**ខ-ការការពារចំពោះកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលរួមក្នុងសហជីព ឬស្ថាបនិកសហជីពៈ**

ចំពោះកម្មករនិយោជិតដែលជាស្ថាបនិក ឬដែលស្ម័គ្រចិត្តចូលរួមជាសមាជិកសហជីព ត្រូវទទួលបានការការពារដូចប្រតិភូបុគ្គលិកចាប់ពីថ្ងៃដាក់ពាក្យសុំចុះបញ្ជិកា រហូតដល់ ៣០ ថ្ងៃ ក្រោយការចុះបញ្ជិកាសហជីព ។

**គ-ការការពារចំពោះថ្នាក់ដឹកនាំសហជីពៈ**

ថ្នាក់ដឹកនាំសហជីពត្រូវបានការការពារដូចប្រតិភូបុគ្គលិក ដូចមានចែងក្នុងមាត្រា ២៨២ និងមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ ។

ប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ប្រការ ៣ កថាខ័ណ្ឌទី ៣ ចែងថា *"កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះ មានរយៈពេល ៤៥ ថ្ងៃមុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនោះ មិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពនេះ តាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ........."*។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីជាប្រការ ៣ នៃប្រកាសនេះ តំរូវឱ្យសហជីពត្រូវជូនដំណឹងទៅនិយោជកក៏ដោយ ក៏ប្រការនេះមិនបានកំណត់ច្បាស់លាស់ថា ការមិនបានជូនដំណឹងនេះ បេក្ខភាពថ្នាក់ដឹកនាំសហជីព ត្រូវបាត់បង់ការការពារនោះទេ ។ ដោយឡែកនៅក្នុងប្រការ ៤ នៃប្រកាសនេះ បានកំណត់យ៉ាងច្បាស់ថា ដើម្បីទទួលបានការការពារចំពោះថ្នាក់ដឹកនាំរបស់សហជីព សហជីពត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះ អ្នកដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយដែលទុកជាបានការ ( ប្រការ ៤ កថាខ័ណ្ឌទី ២ នៃប្រកាសលេខ ៣០៥) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីពពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿបានថា និយោជកពិតជាបានទទួលដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពនៅឡើយទេ ។ ប៉ុន្តែ និយោជកទើបតែបានដឹងថា កម្មករទាំងបួននាក់ដែលបានបណ្តេញចេញ គឺជាថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ នៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលប៉ុណ្ណោះ ។ ម្យ៉ាងទៀតដោយសារកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពខ្មែរប្រចាំរោងចក្រ ជាន វៃ មិនច្បាស់លាស់ និងស្មុគស្មាញ ហើយសព្វថ្ងៃសំណុំរឿងចុះបញ្ជិកាសហជីពនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងពិនិត្យ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើការការពារតាមច្បាប់ចំពោះកម្មករទាំងបួននាក់នេះទេ គឺពិចារណាតែលើការបណ្តេញចេញនេះតែប៉ុណ្ណោះ ។

*២-តើការបណ្តេញចេញកម្មករទាំងបួននាក់នេះ ត្រឹមត្រូវតាមច្បាប់ដែរឬទេ?*

នៅក្នុងសវនាការ និយោជកបានលើកអំពីកំហុសរបស់កម្មករទាំងបួននាក់ តែមិនបានចង្អុលបង្ហាញអំពីមាត្រាច្បាប់ ឬចំណុចណាមួយនៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលកម្មករទាំងនោះល្មើសឡើយ ។ កំហុសដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមាន (១)-ជិះម៉ូតូនៅក្នុងបរិវេណរោងចក្រ និង (២)-សម្ងំនៅក្នុងបន្ទប់ទឹកក្នុងម៉ោងធ្វើការ ។

ច្បាប់ស្តីពីការងារ មាត្រា ២៧ ចែងថា *"ទោសវិន័យត្រូវតែសមាមាត្រស្របទៅនឹងទំងន់នៃកំហុស ...."* ។

ច្បាប់ស្តីពីការងារ មាត្រា ៧៤ ចែងថា *"កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន ។ ......... ក៏ប៉ុន្តែគ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបានដោយគ្មានហេតុផលសមរម្យ ទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុនឡើយ "* ។ <u>និយោជកអាចរំលាយកិច្ចសន្យាការងារគ្មានថិរវេលាកំណត់របស់កម្មករទាំងបួននាក់តាមឆន្ទៈរបស់ខ្លួនបាន លុះត្រាតែមានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយារបស់អ្នកទាំងនោះ យោលទៅតាមភាពចាំបាច់របស់ក្រុមហ៊ុន ហើយត្រូវគិតអំពីទណ្ឌកម្មឱ្យបានសមស្របទៅនឹងកំហុសរបស់ពួកគេផងដែរ ។</u>

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យលើបទបញ្ជាផ្ទៃក្នុងប្រការ ១០ ចំណុច"គ" ទី ១ ដែលបានចែងថា "អ្នកដែលបានចាកចេញពីតួនាទីដោយសេរីក្នុងម៉ោងបំពេញការងារបណ្តាលឱ្យមានបទល្មើសធ្ងន់ ចំពោះវិធានខាងវិន័យសន្តិសុខ និង អនាម័យ ធ្វើឱ្យក្រុមហ៊ុនទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរ " ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អំពើរបស់អ្នកទាំងបួនពិតជាមានធាតុ "ចាកចេញពីតួនាទីដោយសេរីក្នុងម៉ោងបំពេញការងារ" មែន ប៉ុន្តែ និយោជកមិនបានបង្ហាញភស្តុតាងអំពីការខូចខាតដល់ក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរនោះទេ ។ ម្យ៉ាងទៀត ក្រោយពីបាន

ពិនិត្យលើប្រការ ១០ ចំណុច"គ" ទី ១៧ ដែលចែងថា *ចំពោះអ្នកដែលមិនគោរពវិន័យរោងចក្រ មានអាកប្ប-កិរិយាមិនល្អ មិនស្តាប់បង្គាប់អ្នកទទួលខុសត្រូវ ចាត់ទុកថា មិនមានគុណសម្បត្តិគ្រប់គ្រាន់ ត្រូវលាឈប់ពីការងារដោយស្ម័យប្រវត្តិ* ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានធាតុផ្សំខ្លះ តែចំណុចនេះហាក់ដូចជាទុកសិទ្ធិឱ្យកម្មករនិយោជិតលាឈប់ពីការងារដោយស្ម័គ្រចិត្ត ដែលផ្ទុយពីចំណុចវិវាទនេះ គឺភាគីនិយោជកជាអ្នកបណ្តេញកម្មករទាំងបួននាក់ចេញពីការងារទៅវិញ ។ ដូច្នេះ ក្រោយពីពិនិត្យលើច្បាប់ស្តីពីការងារ ក៏ដូចជាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាន វ៉ៃ ដែលបានចុះទិដ្ឋការរួចហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កំហុសទាំងនេះមិនមែនជាកំហុសធ្ងន់ឡើយ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កំហុសទី (១)-ជិះម៉ូតូនៅក្នុងបរិវេណរោងចក្រ ជាកំហុសដែលបានកំណត់នៅក្នុងប្រការ ១០ ចំណុច"ក" ទី ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាន វ៉ៃ ដែលបានចែងថា *"រំខានដល់សណ្តាប់ធ្នាប់ការងារ ឬ ល្មើសវិន័យ សុវត្ថិភាព អនាម័យ ហើយកំហុសនេះមិនជាធ្ងន់ធ្ងរ"* ។ ឯកំហុសទី (២)-សម្ងំនៅក្នុងបន្ទប់ទឹកក្នុងម៉ោងធ្វើការ ជាកំហុសដែលបានកំណត់នៅក្នុងប្រការ ១០ ចំណុច"ក" ទី ២ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាន វ៉ៃ ដែលបានចែងថា *"ក្នុងម៉ោងធ្វើការចាកចេញពីតួនាទីដោយសេរី "* ។ កំហុសកំណត់នៅក្នុងចំណុច"ក" ប្រការ ១០ នៃបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន គឺជាប្រភេទកំហុសស្រាល ។

ម្យ៉ាងទៀតនៅក្នុងប្រការ ១០ នៃបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ជាន វ៉ៃ នេះដែរ បានកំណត់ថា *" កម្មករនិយោជិតណា ដែលមានកំហុសស្រាល ត្រូវទទួលការណែនាំអប់រំដោយផ្ទាល់មាត់លើកទី ១ បើមិនកែប្រែ ត្រូវធ្វើការអប់រំលើកទី ២ ដោយមានសរសេរជាលាយលក្ខណ៍អក្សរ ហើយបើនៅតែមិនរាងចាលបន្តទៀត ត្រូវបញ្ឈប់ពីការងារ "* ។ ប៉ុន្តែ ជាក់ស្តែង ភាគីនិយោជកបានទទួលស្គាល់ថា និយោជកមិនបានចាត់វិធានការខាងវិន័យចំពោះកម្មករទាំងបួននាក់នេះ ស្របតាមប្រការ ១០ នៃបទបញ្ជាផ្ទៃក្នុងនេះឡើយ ។

ផ្អែកលើហេតុផលខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបណ្តេញកម្មករឈ្មោះ **យ៉ិក ម៉ៅ វិន វណ្ណា តេន រាម** និង **នួន សារ៉ាន់** គឺផ្ទុយពីប្រការ ១០ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាន វ៉ៃ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចប្រើប្រាស់អំណាចយុត្តាធិការរបស់ខ្លួន តាមប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ប្រការ ៣៤ ចំណុច "ក" ដែលបានចែងថា *"បញ្ជាអោយកម្មករនិយោជិតដែលបានបណ្តេញចេញឱ្យចូលធ្វើការវិញ នៅក្នុងតំណែងចាស់ ឬតំណែងសមរម្យណាមួយ"* ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេច :

# <u>**បន្ទាប់**</u>

បង្គាប់ឱ្យក្រុមហ៊ុន ជាន វៃ ហ៊្សូស ខូអិលធីឌី ទទួលយកកម្មករឈ្មោះ **យ៉ិក ម៉ៅ** ឈ្មោះ **រិន វណ្ណា** ឈ្មោះ **តែន រាម** និងឈ្មោះ **នួន សារ៉ាន់** ចូលធ្វើការវិញ និងបើកប្រាក់ឈ្នួលទាំងអស់ ចាប់ពីថ្ងៃចេញសេចក្តីបង្គាប់នេះ ។

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

## **ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ឹង សុទ្ធី**

ហត្ថលេខា: -----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ប៉ែន ប៊ុនឈា**

ហត្ថលេខា: -----------------------------